YUNNAN DAILY PRESS GROUP
No.160

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី 26 លេខ 7682 ថ្ងៃសុក្រ ទី 13 ខែ កក្កដា ឆ្នាំ 2018

## លោកហោ ណាំហុង ប្រទេសកម្ពុជា និងចិនមិនគ្រាន់តែជាមិត្តល្អប៉ុណ្ណោះទេថែមទាំងក៏ជាបងប្អូនល្អទៀតផង

ក្នុងឱកាសអបអរសាទរខួបលើកទី៦០ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជា និងចិន លោក ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រីកម្ពុជា បានផ្តល់បទសម្ភាសន៍ជាមួយអ្នកកាសែតចិនថា មិត្តភាពកម្ពុជា និងចិនមានប្រវត្តិសាស្ត្រយូរលង់ណាស់មកហើយ ។ ប្រទេសទាំងពីរមិនគ្រាន់តែជាមិត្តល្អប៉ុណ្ណោះទេ ថែមទាំងក៏ជាបងប្អូនល្អទៀតផង ។ ជំនួយរបស់ប្រទេសចិនបាន និងកំពុងដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៃប្រទេសកម្ពុជា ។

លោកមានប្រសាសន៍ថា ក្រោយពីបង្កើតទំនាក់ទំនងការទូតជាផ្លូវការនៅឆ្នាំ១៩៥៨រៀងមក ថ្នាក់ដឹកនាំជាន់ខ្ពស់នៃប្រទេសទាំងពីរកម្ពុជា និងចិនបានរក្សាការផ្លាស់ប្តូរទស្សនកិច្ចជាញឹកញាប់ ។ កិច្ចសហប្រតិបត្តិការទ្វេភាគីត្រូវបានពង្រឹង និងពង្រីកឱ្យកាន់តែស៊ីជម្រៅចំណែកទំនាក់ទំនងរវាងភាគីទាំងពីរក៏បានរីកចម្រើនទៅមុខឥតឈប់ឈរ ។ នៅឆ្នាំ២០១០ ប្រទេសកម្ពុជា និងចិនបានបង្កើតកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ។

លោកបន្តទៀតថា ក្រោមគំនិតផ្តួចផ្តើម"ខ្សែក្រវាត់មួយ និងផ្លូវមួយ" ប្រទេសកម្ពុជានិងចិនបានទទួលលទ្ធផលជាផ្លែផ្កាថ្មីក្នុងការធ្វើកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងការផ្លាស់ប្តូរផ្នែកវប្បធម៌ជាដើម ។

នៅពេលនិយាយចំពោះគម្រោងវិនិយោគរបស់សហគ្រាសចិននៅប្រទេសកម្ពុជាលោកបានធ្វើបទឧទ្ទេសនាមយ៉ាងក្បោះក្បាយ ។ លោកបានបញ្ជាក់ថា ប្រទេសចិនបានសាងសង់ស្ពាន និងផ្លូវច្រើននៅប្រទេសកម្ពុជា ។ ផ្លូវថ្នល់ដែលត្រូវបានសាងសង់រួចរាល់និងកំពុងដំណើរការសាងសង់ដោយប្រទេសចិនមានប្រវែងសរុបជិត ៣.០០០គីឡូម៉ែត្រ ចំណែកស្ពានធំដែលសាងសង់ដោយប្រទេសចិនមានចំនួន ៧ ខ្សែ ។ ជាពិសេសគម្រោងសាងសង់ស្ពានធំទី៨ដែលវិនិយោគដោយប្រទេសចិននោះ បានបើកការដ្ឋានសាងសង់ និងកំពុងដំណើរការសាងសង់យ៉ាងរលូន ។ ក្នុងឱកាសខួបទី ៦០ ឆ្នាំនៃការបង្កើតទំនាក់ទំនងការទូតកម្ពុជានិងចិនសហគ្រាសចិនបានចូលរួមអនុវត្តន៍គម្រោងព្រលានយន្តហោះអន្តរជាតិថ្មីនៅខេត្តសៀមរាប និងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ ។ គម្រោងទាំងពីរនេះមានសារសំខាន់សម្រាប់ជំរុញការអភិវឌ្ឍន៍នៃប្រទេសកម្ពុជា ។

លោក សង្កត់ធ្ងន់ថា បើគ្មានធនធានមនុស្ស កម្ពុជាមិនអាចទទួលការរីកចម្រើនបានទេ ។ សព្វថ្ងៃ និស្សិតខ្មែរជាង១.២០០នាក់បានទទួលអាហារូបករណ៍ពីរដ្ឋាភិបាលចិន ។ និស្សិតដែលបញ្ចប់ការសិក្សានៅប្រទេសចិនទាំងនោះនឹងត្រឡប់មកស្រុកខ្មែរវិញដើម្បីចូលរួមការអភិវឌ្ឍន៍នៃមាតុប្រទេសហើយជាធនធានមនុស្សសំខាន់សម្រាប់ការអភិវឌ្ឍនៃប្រទេសកម្ពុជា ៕

**ដោយ ហ៊្វឹង ហួយ (ស៊ីនហួចិន)**

## មន្ត្រីរាជការអនុវត្តន៍ច្បាប់ជាន់ខ្ពស់កម្ពុជារៀនបទពិសោធន៍នៅខេត្តយូនណាន




*មន្ត្រីកម្ពុជា (ឆ្វេង) ត្រូវបានគេ បង្ហាញសៀវភៅ " លោកប្រធានាធិបតីស៊ី ជីនភីង ការគ្រប់គ្រងចិន " (រូបថត ដោយ Wu Ping )*

ពេលថ្មីៗនេះ វគ្គបណ្តុះបណ្តាលមន្ត្រីរាជការអនុវត្តន៍ច្បាប់ជាន់ខ្ពស់នៃប្រទេសកម្ពុជា (ប្រយុទ្ធប្រឆាំងគ្រឿងញៀន) ឆ្នាំ២០១៨ ដែលរៀបចំដោយក្រសួងសន្តិសុខសាធារណៈប្រទេសចិន និងទទួលបន្ទុករៀបចំជាក់ស្តែងដោយវិទ្យាស្ថាននគរបាលខេត្តយូនណានបានរៀបចំពិធីបិទវគ្គនៅវិទ្យាស្ថាននគរបាលខេត្តយូនណាន។ ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវ ការផ្លាស់ប្តូរទស្សនៈ និងកម្មវិធីទស្សនាជាក់ស្តែងអស់ពេល១៥ថ្ងៃនោះ សិក្ខាកាមខ្មែរ១៥នាក់បានបញ្ចប់ការសិក្សាដោយជោគជ័យ ។

តាមប្រភពព័ត៌មានពីស្ថាប័នពាក់ព័ន្ធបានឱ្យដឹងថា ក្នុងអំឡុងពេលពីចុងខែមិថុនាដល់ដើមខែកក្កដាឆ្នាំនេះ សិក្ខាកាមជាមន្ត្រីរាជការខ្មែរទាំង១៥នាក់ បានសិក្សាស្រាវជ្រាវអំពីស្ថានការណ៍ និងយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងគ្រឿងញៀនលើពិភពលោក ការផ្សព្វផ្សាយ និងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន ការកសាងសមត្ថភាពដឹកនាំ និងគ្រប់គ្រងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននិងវិធីសាស្ត្រនៃការបង្ក្រាបបទល្មើសគ្រឿងជាដើម។ ក្នុងឱកាសនោះ គ្រូបង្រៀន និងនិស្សិត អនុបណ្ឌិតមួយចំនួន ដែលមកពីផ្នែកមុខវិជ្ជាអំពីការបង្ក្រាបបទល្មើសគ្រឿងញៀន ផ្នែកនីតិប្បញ្ញត្តិ និងផ្នែកអប់រំនគរបាលអន្តរជាតិនៃវិទ្យាស្ថាននគរបាលខេត្តយូនណានបានចូលរួមផ្លាស់ប្តូរ ទស្សនៈជាមួយសិក្ខាកាមខ្មែរអំពីការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន។៕ **ដោយអ៊ូ ភីង**

## និស្សិតបញ្ចប់ការសិក្សាហើយទៅធ្វើជាមន្ត្រីរាជការប្រចាំភូមិជួយកសិករដាំដើមតែដើរឆ្ពោះទៅកាន់ជីវភាពធូរធារ

ក្រោយពីបញ្ចប់ការ សិក្សាពីសាកលវិទ្យាល័យលោកលី ជីនសៀន បានចូលទៅធ្វើការជាមន្ត្រីរាជការប្រចាំភូមិនៅក្នុងភូមិសុងសាន ឃុំវិនឈួន ស្រុកឆាងនីង ។ លោកធ្លាប់រៀនមុខវិជ្ជាអំពីការថែរក្សារុក្ខជាតិនៅសាកលវិទ្យាល័យកសិកម្មខេត្តយូនណាន ។ នៅខែវិច្ឆិកាឆ្នាំ២០១៥ លោកបានចុះទៅធ្វើការនៅភូមិសុងសាន ។ ក្រោយពីនោះលោកបានខិតខំប្រឹងប្រែងដើម្បីផ្ទេរ និងផ្សព្វផ្សាយទស្សនៈថ្មី និងបច្ចេកទេសថ្មីចំពោះកសិករដាំដើមតែ ដូចជាបច្ចេកទេសដាំដុះដើមតែ គ្រប់គ្រងចម្ការតែ បេះយកស្លឹកតែ និងកែច្នៃស្លឹកតែជាដើម ។



*លោក លី ជីនសៀន (បុរស ដែលពាក់វ៉ែនតា) កំពុងបង្រៀនអ្នកភូមិអំពីវិធីដើម្បីបេះស្លឹកតែ (រូបថតដោយ Zhang Tong )*

ក្នុងរយៈពេលជាងពីរឆ្នាំកន្លងទៅនោះ លោកបានរៀបចំវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសដាំដើមតែជាង៣០លើកនៅភូមិសុងសាន ដែលមានការចូលរួមពីកសិករដាំដើមតែជាង៥០០នាក់ ។ មិនតែប៉ុណ្ណោះ លោកបានរៀបចំវគ្គបណ្តុះបណ្តាលអំពីវប្បធម៌ស្លឹកតែសម្រាប់សិស្សនិស្សិតជាង២០០នាក់ និងអ្នកភូមិជាង១០០នាក់ ។ ក្រៅពីនេះ លោកបានសុំឱ្យឪពុកម្តាយទៅខ្ចីប្រាក់ឥណទានដើម្បីជួលរោងចក្រកែច្នៃស្លឹកតែចាស់មួយ ហើយរកដៃគូពាណិជ្ជកម្មដើម្បីបង្កើតជាក្រុមហ៊ុនស្លឹកតែមួយ ដែលបានត្រួសត្រាយនូវផ្លូវអភិវឌ្ឍន៍ថ្មីនៃអាជីវកម្មដាំដើមតែ និងកែច្នៃស្លឹកតែតាមរយៈរូបមន្ត "និស្សិតបញ្ចប់ការសិក្សា ហើយធ្វើជាមន្ត្រីរាជការប្រចាំភូមិ+ក្រុមហ៊ុន+កសិករដាំដើមតែ" ។

ក្នុងដំណើរនៃការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រដោយតម្រង់ទិស លោក លី ជីនសៀន ទទួលខុសត្រូវចំពោះការជួយគ្រួសារក្រីក្រចំនួនពីរ ។ ឱ្យតែមានពេលទំនេរ លោកនឹងទៅសាកសួរសុខទុក្ខគ្រួសារទាំងពីរ ហើយផ្តល់ការណែនាំដល់ពួកគេអំពីបច្ចេកទេសដាំដើមតែ និងគ្រប់គ្រងចម្ការតែដោយវិធីវិទ្យាសាស្ត្រ ។ ជាពិសេស លោកបានបន្ថែមប្រាក់០,៥យ័ន/គីឡូលើសពីតម្លៃទីផ្សារដើម្បីទិញយកផលិតផលតែពីគ្រួសារក្រីក្រទាំងពីរនោះ ។

អ្នកភូមិឈ្មោះ លី យីនស៊ូ មកពីគ្រួសារមួយក្នុងចំណោមគ្រួសារ ទាំងពីរដែលទទួលខុសត្រូវកាត់បន្ថយភាពក្រីក្រដោយលោក លី ជីនសៀន ។ លី យីនស៊ូ បានប្រាប់អ្នកកាសែតដោយ មានចិត្តរំភើបថាឱ្យក្មួយលី ជីនសៀន មកជួយគ្រួសារខ្ញុំពិតជាល្អណាស់ ! គាត់មិនត្រឹមតែបង្រៀនយើងឱ្យចេះដាំដើម តែ គ្រប់គ្រងចម្ការតែ និងចេះបេះយកស្លឹកតែនោះទេហើយបានបន្ថែមប្រាក់០,៥យ័ន/គីឡូដើម្បីទិញយកស្លឹកតែពីខ្ញុំ។ នៅឆ្នាំ២០១៧ គ្រួសារលី-យីនស៊ូ បានទទួលចំណូល២,៤ម៉ឺនយ័នតាមរយៈការដាំដើមតែកើនឡើង ៥.០០០យ័នធៀបនឹងឆ្នាំ២០១៦ ៕

**ដោយយ៉ាងជឹហួយ**

## គម្រោងជំនួយរបស់ចិនផ្តល់ទឹកស្អាតដល់ប្រជាជនខ្មែរមួយសែននាក់

នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ ២០១៨ គម្រោងស្រះទឹកមានទំនប់នៅភូមិចំបក់ភ្លោះ ស្រុកពញាឮ ខេត្តកណ្តាលនៃប្រទេសកម្ពុជា ដែលផ្តល់ជំនួយសាងសង់ដោយប្រទេសចិននោះ បានរៀបចំពិធីផ្ទេរ និងប្រគល់ទៅឱ្យភាគីកម្ពុជា ។

តាមការឧទ្ទេសនាមបានឱ្យដឹងថា គម្រោងស្រះទឹកមានទំនប់លេខ ១៧ នេះជាវិស្វកម្មដំណាក់កាលទី១ នៃគម្រោងផ្គត់ផ្គង់ទឹកស្អាតតាមតំបន់ជនបទ ដែលប្រទេសចិនផ្តល់ជំនួយដល់ប្រទេសកម្ពុជា ។ ចាប់ពីខែកក្កដា ឆ្នាំ ២០១៧មក ក្រុមហ៊ុន China National Nuclear Corporation ដែលជាក្រុមហ៊ុនម៉ៅការ EPC រួមនៃគម្រោងដំណាក់-កាលទី១នេះ បានចាប់ផ្តើមជីកអណ្តូងទឹកជ្រៅចំនួន៨៤៦ ស្រះទឹកធម្មតាចំនួន ៤៥ និងស្រះទឹកមានទំនប់ចំនួន២៨ នៅខេត្តចំនួនប្រាំមួយ ក្នុងប្រទេសកម្ពុជា រួមមានខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កណ្តាល ត្បូងឃ្មុំ និងស្វាយរៀង ។ គិតមកដល់ពេលនេះ ក្រុមហ៊ុនបានបញ្ចប់ការជីកអណ្តូងទឹក និងស្រះទឹកជាស្ថាពរ ហើយបានផ្ទេរ និងប្រគល់ទៅឱ្យភាគីកម្ពុជា១០០ភាគរយ ។ គម្រោងដំណាក់កាលទី១ នេះអាចផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជនខ្មែរមួយសែននាក់ ដែលរស់នៅក្នុងខេត្តទាំងប្រាំមួយនៃប្រទេសកម្ពុជា៕ **ដោយ យូ ជាំងនីង**




*រូបថតមួយសន្លឹកដែលត្រូវ បានថតនៅពិធីប្រគល់អណ្តូងទឹកស្អាតដល់ប្រជាពលរដ្ឋខ្មែរ (រូបថតដោយ Yu Jiangning )*

## អ្នកកាប់ឈើរាប់ពាន់នាក់ក្លាយជាអ្នកដាំដើមឈើនៅស្រុកឌីឈីងខេត្តយូនណាន

នៅទសវត្សរ៍ឆ្នាំ ៩០ សតវត្សរ៍មុនទីលានរុក្ខកម្មសៀវជុងទាននៅស្រុកឌីឈីងជាទីតាំងកាប់ឈើរបស់ក្រុមហ៊ុនទិញលក់ឈើនៅក្នុងតំបន់នោះ ។ ក្នុងក្រុមហ៊ុនទិញលក់ឈើ លោក ហឺ សាវយូវ និងមិត្តរួមការងារជាច្រើនត្រូវទៅកាប់ឈើក្នុងព្រៃជារៀងរាល់ឆ្នាំដើម្បីទទួលបានចំណូលពីអាជីវកម្មលក់ដូរឈើ ។ កាលនោះ អ្នកកាប់ឈើដូចលោក ហឺ សាវយូវ នៅស្រុកឌីឈីង មាន ចំនួន១.៥៤៧ នាក់ ។

ប៉ុន្តែដោយសារធនធានព្រៃឈើត្រូវបានកាប់បំផ្លាញជាបន្តបន្ទាប់ ដែលបណ្តាលឱ្យកើតមានបញ្ហាខ្វះខាតដើមឈើ ភ្នំនីមួយៗបាត់បង់ពណ៌បៃតង ហើយបានបាត់ដីដ៏ច្រើននិងបានប៉ះពាល់ដល់អេកូ-ធម្មជាតិ ។ ជាពិសេស នៅឆ្នាំ ១៩៩៨ គ្រោះទឹកជំនន់យ៉ាងធ្ងន់ធ្ងរបានផ្ទុះឡើងនៅតាមទន្លេយ៉ាងសេ ដូច្នេះរដ្ឋាភិបាលចិនបានសម្រេចចិត្តហាមប្រាមមិនឱ្យកាប់ឈើនៅផ្នែកខាងលើនៃទន្លេជីនសា និងទន្លេឡានឆាង ។ នៅឆ្នាំដដែលនោះ រដ្ឋបាលស្រុកឌីឈីង បានប្រកាសហាមមិនឱ្យកាប់ឈើនៅគ្រប់ទីកន្លែង ហើយបានបញ្ជាឱ្យស្ថាប័នពាក់ព័ន្ធទៅពិនិត្យការងារឱ្យទាន់ពេលវេលា និងរឹបអូសឧបករណ៍កាប់ឈើទាំងអស់ ។ តាំងពីពេលនោះមក អ្នកកាប់ឈើទាំង១.៥៤៧នាក់នៅស្រុកឌីឈីងបានក្លាយទៅជាអ្នកដាំដើមឈើវិញ និងបានដើរតួជាអ្នកថែរក្សាព្រៃឈើក្នុងតំបន់ ។ នេះបានធ្វើឱ្យជីវិតរបស់លោក ហឺ សាវយូវ និងមិត្តរួមការងាររបស់លោកមានការប្រែប្រួលជាខ្លាំង ។នៅរដូវផ្ការីក និងរដូវក្តៅពួកគេត្រូវតែឡើងភ្នំដាំដើមឈើរីឯនៅរដូវរងាពួកគេត្រូវទៅយាមល្បាតក្នុង ភ្នំព្រៃដើម្បីការពារកុំឱ្យកើតមាន អគ្គិភ័យ ។

ក្នុងរយៈពេល ២០ ឆ្នាំកន្លងទៅនោះ លោក ហឺ សាវយូវ និងមិត្តរួមការងាររបស់លោកបានចូលរួមថែរក្សា និងបណ្តុះព្រៃឈើទំហំ ៦៩៦០ ហិកតា និងដាំដើមឈើជាង ១.១៣៧ ហិកតា ដែលបានធ្វើឱ្យធនធានព្រៃឈើនៅឃុំសៀវជុងទានទទួលបានការរីកចម្រើនជានិរន្តរ៍ និងបានធ្វើឱ្យអេកូ-បរិស្ថាននៅទីនោះកាន់តែមានភាពល្អប្រសើរជាមុន ។ បច្ចុប្បន្នបរិមាណព្រៃឈើនៅស្រុកឌីឈីងបានកើនឡើងពី ២២៧ លានម៉ែត្រគុបដល់ទៅ២៧៣លានម៉ែត្រគុប ចំណែកអត្រាគ្របដណ្តប់ដោយព្រៃឈើបានកើនឡើងពី ៦៥,៤ ភាគរយ ដល់ទៅ ៧៥,០៣ភាគរយ ។ បរិមាណ និងទំហំនៃព្រៃឈើនៅស្រុកឌីឈីងសម្រេចបានកំណើនប្រកបដោយផ្លែផ្កា ។៕ **ដោយ ភឹង ស៊ី**